




# ជំរឿនកសិកម្មកម្ពុជា ឆ្នាំ ២០១៣

## សាវតា

ទោះបីវិស័យកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសារៈសំខាន់ក៏ដោយ កម្ពុជាពុំធ្លាប់មានការធ្វើជំរឿនកសិកម្មឡើយ។ កម្ពុជាពុំមានក្របខ័ណ្ឌសមស្រប សម្រាប់បង្កើត និងធ្វើការអង្កេតកសិកម្ម ដូចដែលកំពុងអនុវត្តឡើយ ហើយក៏ពុំមានទិន្នន័យគោលសម្រាប់ប្រើប្រាស់ឡើយ។ ជាផលវិបាក ព័ត៌មានស្ថិតិអំពីកសិកម្មដែលបានពីការប្រមូលទិន្នន័យបច្ចុប្បន្ននេះ គឺចាស់ហួសសម័យ មិនអាចយកជាការបាន និងពុំពេញលេញឡើយ។ ស្ថានភាពនេះ ធ្វើឲ្យខូចដំណើរការកសាងផែនការដែលផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ និងការកសាងគោលនយោបាយដែលទាក់ទងនឹងការអភិវឌ្ឍន៍កសិកម្ម និងសន្តិសុខស្បៀង។

អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយពី FAO ដើម្បីធ្វើជំរឿនកសិកម្មជាលើកដំបូងបង្អស់នៅក្នុងប្រទេស ដើម្បីបំពេញព័ត៌មានដែលខ្វះខាត និងផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការអង្កេតនានាដែលអាចទុកចិត្តបានទៅអនាគត។

ជាការឆ្លើយតប អង្គការ FAO បានជួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើតគម្រោងមួយ សម្រាប់រៀបចំ និងធ្វើជំរឿន ដែលនឹងទទួលមូលនិធិគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ចំនួនបីគឺ USAID, AusAID និង Sweden។ អង្គការ FAO នឹងផ្តល់ការគាំទ្រ សម្រាប់ការងារត្រៀមរៀបចំ តាមរយៈកម្មវិធីសហប្រតិបត្តិការបច្ចេកទេសរបស់ខ្លួន។



## លទ្ធផល និងដែនកំណត់នៃជំរឿន

លទ្ធផលចំបងនៃជំរឿន គឺថា អ្នកធ្វើសេចក្តីសម្រេចនានាដែលរួមទាំងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការនានា និងអ្នកប្រើប្រាស់ដទៃទៀត នឹងមានលទ្ធភាពប្រើប្រាស់ទិន្នន័យពិស្តារដែលអាចទុកចិត្តបាន និងថ្មីៗ ស្តីពីវិស័យកសិកម្ម។

លទ្ធផលទីពីរ គឺកំណើនសមត្ថភាពនៅក្នុងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ (NIS-MoP) និងនាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DPS-MAFF) ក្នុងការធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងនេះ និងអនុវត្តការងារអង្កេតនៅចន្លោះអំឡុងពេលជំរឿនទៅតាមបច្ចេកទេសសមស្រប។

ដើម្បីសំរេចការងារនេះ គម្រោងនឹងបង្កើតលទ្ធផលដូចតទៅ៖

១. ពង្រឹងប្រព័ន្ធស្ថិតិ និងស្ថាប័នកសិកម្ម (NIS-MoP, DPS-MAFF) ដែលមានបុគ្គលិកនៅគ្រប់លំដាប់ថ្នាក់ បានទទួលការបណ្តុះបណ្តាល និងមានសមត្ថភាពក្នុងការបង្កើតទិន្នន័យជាទៀងទាត់ប្រកបដោយគុណភាពខ្ពស់ ដែលជាតម្រូវការសម្រាប់វិស័យកសិកម្ម។

២. ព័ត៌មានស្ថិតិពិស្តារ សុក្រឹត្យ និងថ្មីៗ ស្តីពីស្ថានភាព និងរចនាសម្ព័ន្ធនៃវិស័យកសិកម្ម នៅតាមអង្គភាពរដ្ឋបាលថ្នាក់ក្រោមបំផុតក្នុងប្រទេសកម្ពុជា។

៣. ក្របខ័ណ្ឌសម្រាប់ប្រមូលយកសំណាក ដើម្បីការធ្វើអង្កេតកសិកម្ម ដែលត្រូវអនុវត្តនៅក្រោយការធ្វើជំរឿន។

ជំរឿនកសិកម្ម ឆ្នាំ២០១៣ រួមមាន ផ្នែកសំខាន់ៗដូចតទៅ៖

- សំណុំលក្ខណៈនៃចំណែកដីកសិកម្ម៖ ផ្ទៃដី ទីតាំង ការប្រើប្រាស់ដីចំបងៗ កម្មសិទ្ធិដី ចំនួនក្បាលដី ប្រភេទដំណាំដែលបានដាំ ផ្ទៃដីដាំដំណាំ ។ល។
- ទម្លាប់ធ្វើកសិកម្ម និងសេវាកសិកម្ម
- សំណុំលក្ខណៈនៃគ្រួសារកាន់កាប់ដីកសិកម្ម
- ការប្រើប្រាស់ពលករស៊ីឈ្នួល
- សំណុំលក្ខណៈនៃសកម្មភាពចិញ្ចឹមសត្វ
- សំណុំលក្ខណៈនៃសកម្មភាពវារីវប្បកម្ម
- ព័ត៌មាននៅកម្រិតភូមិ ដូចជា អំពីស្ថានភាពដី ប្រភេទដីបរិក្ខារដែលមាន និងសម្បទានានា។

USAID FROM THE AMERICAN PEOPLE · SWEDEN · Australian AID · National Institute of Statistics, Ministry of Planning, Cambodia · FAO



ជម្រឿននេះនឹងធ្វើនៅតាមតំបន់ជនបទ និងទីក្រុងទាំងអស់ ក្នុងខេត្តចំនួន ២៣ និងកន្លែងមួយចំនួនក្នុងក្រុងភ្នំពេញ។

## ការធ្វើជម្រឿន

ក្នុងអំឡុងពេលរៀបចំការធ្វើជម្រឿន ខែឧសភា ឆ្នាំ ២០១២ ដល់ខែមីនា ឆ្នាំ ២០១៣ មានការកំណត់អំពីវិស័យវងនានាដែលត្រូវបញ្ចូលនៅក្នុងជម្រឿន រៀបចំបញ្ជីសំណួរ និងបណ្តុះបណ្តាលបុគ្គលិក NIS-MoP និង DPD-MAFF។ ក្រៅពីនេះ ក៏មានការកំណត់អំពីអ្នកកត់ត្រា អ្នកគ្រប់គ្រងការធ្វើជម្រឿន និងផ្តល់ការបណ្តុះបណ្តាល ដល់អ្នកទាំងនោះផងដែរ ដោយផ្អែកលើឯកសារណែនាំសម្រាប់ការធ្វើជម្រឿន ដែលបានរៀបចំ និងបង្កើតឡើងសម្រាប់ការធ្វើជម្រឿននៅកម្ពុជា។ បញ្ជីសំណួរត្រូវបានដាក់ឲ្យអនុវត្តសាកល្បងជាច្រើនលើកនៅក្នុងតំបន់កសិអេកូឡូស៊ីខុសៗគ្នា ដើម្បីធ្វើឲ្យសំណួរមានភាពច្បាស់លាស់ និងអាចឲ្យអ្នកឆ្លើយងាយយល់។ ជម្រឿនសាកល្បងបានអនុវត្ត នៅខែធ្នូ ឆ្នាំ ២០១២ ដើម្បីពិនិត្យមើលដំណើរការជម្រឿនទាំងមូល។

ជុំទីមួយនៃការធ្វើជម្រឿនទាំងមូលនៅតាមចំណុចភូមិសាស្ត្រ ត្រូវបានគ្រោងចាប់ផ្តើមនៅខែ មេសា-ឧសភា ឆ្នាំ២០១៣ និងត្រូវអនុវត្តរយៈពេលពីរខែ។ ជុំទីពីរនៃជម្រឿនត្រូវបានគ្រោងចាប់ផ្តើមនៅខែសីហា ដល់ខែ កញ្ញា និងមានរយៈពេល ៤៥ ថ្ងៃ។ ជម្រឿនឆ្នាំ២០១៣នេះ នឹងត្រូវការអ្នកកត់ត្រាប្រមាណ ៣៥០០នាក់ និងអ្នកគ្រប់គ្រងប្រមាណ ៥០០នាក់ ដើម្បីអនុវត្តការងារនៅតាមចំណុចភូមិសាស្ត្រ ដែលរួមមានការអង្កេតគ្រួសារទាំងអស់នៅក្នុងប្រទេស (លើកលែងតែអ្នកទីក្រុងសុទ្ធសាធនៅក្នុងក្រុងភ្នំពេញ) ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលពាក់ព័ន្ធនៅក្នុងសកម្មភាពកសិកម្ម (ត្រូវបានប៉ាន់ស្មានថាមានប្រមាណ២,៧លានគ្រួសារ)។ គ្រួសារនីមួយៗទាំងនេះនឹងត្រូវសម្ភាសន៍ដោយប្រើប្រាស់បញ្ជីសំណួរមួយទៅតាមម៉ូឌុល។

ប៉ុន្មានសប្តាហ៍ក្រោយមក ប្រមាណ៥ភាគរយនៃគ្រួសារទាំងនេះ នឹងត្រូវទទួលការសម្ភាសន៍ឡើងវិញ និងសួរសំណួរជាក់លាក់ជាងមុន ដោយផ្អែកលើបញ្ជីសំណួរក្នុងម៉ូឌុលបន្ថែមមួយ ឬច្រើន ក្នុងចំណោមម៉ូឌុលបន្ថែមចំនួនប្រាំ។

បន្ទាប់ពីការអង្កេតនៅតាមចំណុចភូមិសាស្ត្រ មានការចុះលេខសំគាល់ចម្លើយ ការពិនិត្យគុណភាពព័ត៌មាន ការពិនិត្យកែសម្រួល និងវាយបញ្ចូលទិន្នន័យក្នុងតារាង។ ឯកសារបច្ចេកទេសតាមប្រធានបទមួយចំនួន នឹងត្រូវរៀបចំឡើង បន្ទាប់មកនឹងមានការវិភាគពិស្តារលើលទ្ធផល។ ទន្ទឹមនឹងនេះ បុគ្គលិក NIS-MoP និង DPS-MAFF នឹងទទួលការបណ្តុះបណ្តាលបន្ថែមទៀតផងដែរ ដើម្បីកសាងសមត្ថភាព សម្រាប់ធ្វើការបកស្រាយទិន្នន័យ និងធ្វើការអង្កេតជាបន្ថែម និងកែលម្អជម្រឿននេះបន្ថែមទៀត។ ការបោះពុម្ពផ្សាយលទ្ធផលចុងក្រោយនៃជម្រឿននេះ ត្រូវបានរំពឹងថានឹង ធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០១៥។

## ការផ្តល់មូលនិធិ និងភាពជាដៃគូ

ថវិកាប៉ាន់ស្មានសរុបសម្រាប់ជម្រឿនកសិកម្មឆ្នាំ ២០១៣ គឺ ៥,៥លានដុល្លារអាមេរិក ក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជាបានត្រៀមបម្រុងចំនួន ១,៤លានដុល្លារអាមេរិក។ ម្ចាស់ជំនួយចំនួនបីគឺ USAID, AusAID និង Sweden ក៏បានប្តេជ្ញាផ្តល់ការគាំទ្ររបស់ខ្លួន (ប្រមាណ ១,៥លានដុល្លា ១លានដុល្លា និង ១,២លានដុល្លារអាមេរិក)ផងដែរ។ តាមរយៈកម្មវិធីសហប្រតិបត្តិការបច្ចេកទេសរបស់ខ្លួន អង្គការ FAO បានផ្តល់ការគាំទ្រសម្រាប់ការងារត្រៀមរៀបចំ ដែលមានជំនាញបច្ចេកទេស និងសម្ភារៈក្នុងតម្លៃ ៣៦៩.០០០ដុល្លារអាមេរិក។

ជម្រឿននេះអនុវត្ត នៅក្រោមការទទួលខុសត្រូវរួមរបស់ NIS-MoP។ ដោយសារតែកម្រិតបច្ចេកទេសនៃការអង្កេតនេះ ជម្រឿននឹងត្រូវអនុវត្តរួមគ្នារវាងNIS-MoP និងDPS-MAFF។ការិយាល័យស្ថិតិប្រចាំនៅកម្ពុជា នៃផ្នែកស្ថិតិនៅការិយាល័យកណ្តាលនៃអង្គការ FAO និងអ្នកជំនាញការស្ថិតិជាន់ខ្ពស់នៃការិយាល័យ FAOប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ជាអ្នកដឹកនាំ និងផ្តល់ការគាំទ្របច្ចេកទេស។ នាយកអង្គការ FAO ប្រចាំនៅកម្ពុជាជាអ្នកដឹកនាំរួមលើគម្រោងនេះ។



USAID FROM THE AMERICAN PEOPLE · SWEDEN · Australian AID ជំនួយអូស្ត្រាលី · National Institute of Statistics, Ministry of Planning, CAMBODIA · FAO FIAT PANIS